**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# រវាង
# រោងចក្រ អេវ៉ាយស៊ី ហ្គាម៉ិន ហ្វេកធើរី ឯ.ក
# ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំរោងចក្រ
# ស្តីពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ១៣:០០នាទីរសៀល នៅក្នុងរោងចក្រ អេវ៉ាយស៊ី ហ្គាម៉ិន ហ្វេកធើរី ឯ.ក មានកិច្ចប្រជុំមួយរវាងតំណាងរោងចក្រ នឹងតំណាងកម្មករនិយោជិក។

នៅក្នុងអង្គប្រជុំនេះនាយករោងចក្របានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ន រោងចក្រខ្វះការបញ្ជាទិញ ដែលបណ្តាលឱ្យសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ។
ហេតុដូចនេះរោងចក្រសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន៤៨៨នាក់ (ស្រី ៣២១នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ៦៨៨នាក់ (ស្រី ៤៤៨នាក់) រយៈពេល ៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០២៣។
ក្នុងអំឡុងពេលព្យួរការងារនេះកម្មករនិយោជិកបានឯកភាពទទួលការផ្តល់ជូនរបស់រោងចក្រនូវ ប្រាក់ឧបត្ថម្ភ ចំនួន ៦០ដុល្លា។
ក្នុងករណីមានការកែប្រែនូវលក្ខខណ្ឌណាមួយក្នុងអំឡុងព្យួរកិច្ចសន្យាការងារដែរគោលការណ៍កំណត់ថ្មីរបស់អាជ្ញាធរមានសមត្ថកិច្ច(ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ)នោះការព្រមព្រៀងនឹងអនុវត្តតាមគោលការណ៍ថ្មីនោះ។

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ នឹងបើកជូនបងប្អូនកម្មករនិយោជិត ដូចខាងក្រោម:

- លើកទី១ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ចំនួន ៣០ដុល្លា
- លើកទី២ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ ចំនួន ៣០ដុល្លា។

អង្គប្រជុំបានចប់នៅវេលាម៉ោង ១៤:៣០នាទី រសៀលនាថ្ងៃខែឆ្នាំដដែលប្រកបដោយបរិយាកាសរីករាយ និងស្និត ស្នាល ក្រោមស្មារតីទទួលទូលខុសត្រូវខ្ពស់ និងយោបល់សហការគ្នាយ៉ាងរលូន។

ថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ខេត្តកណ្តាល

ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣

ជ.នាយករោងចក្រ

AYC GARMENT FACTORY CO., LTD.
KINGDOM OF CAMBODIA

Ou Xiao Juan

ស្នាមមេដៃតំណាងកម្មករ និយោជិត និងតំណាងសហជីព